**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ៣២១/១៥ ក.អ.ជ.ប្រក

ថ្ងៃ ពុធ ១១ កើត ខែ បុស្ស ឆ្នាំ មមី ព.ស. ២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ គ.ស ២០១៥

# ប្រកាស

# ស្តីពី

# ការតែងតាំងសមាសភាពក្រុមការងារសកម្មភាពជនពិការ ក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញប្រកាសលេខ ០០១ កសជ.ប្រក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួងស្ថាប័ន
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ ។

**សម្រេច**

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាព ក្រុមការងារសកម្មភាពជនពិការ នៅក្រសួងអភិវឌ្ឍន៍ជនបទដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| ២-ឯកឧត្តម **ឃាង អូម៉ាលី** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ៣-លោក **លី សាវុធ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-លោក **ឡូន តិរម្យ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៥-លោក **ម៉ា សុវណ្ណា** | ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៦-លោក **លាត សំណាង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |
| ៧-លោក **អឿន ឆារិទ្ធ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៨-លោក **គី សុផល** | អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ | សមាជិក |
| ៩-លោក **នង ចន្ថា** | ប្រធានការិយាល័យកិច្ចការទូទៅ និងសន្តិសុខ | សមាជិក |
| ១០-លោក **ម្រៀប រដ្ឋា** | ប្រធានការិយាល័យបុគ្គលិក | សមាជិក |
| ១១-លោកស្រី **កេត ផាន់ណា** | ប្រធានការិយាល័យផ្សព្វផ្សាយ | សមាជិកា |
| ១២-លោក **អៀង ស៊ីថា** | អនុប្រធានការិយាល័យបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |
| ១៣-លោកស្រី **សន សុផល** | អនុប្រធានការិយាល័យកិច្ចការទូទៅ | សមាជិកា |

**ប្រការ ២.-**

ក្រុមការងារសកម្មភាពជនពិការ មានតួនាទី និងភារកិច្ចដូចតទៅ÷

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង
- ជួយរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្រ្តដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង
- លើកសំណើជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាពនៅក្នុងក្រសួង

- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស
- ចូលរួម និងរៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀតនៅក្នុងក្រសួង
- ជួយក្រុមប្រឹក្សាសកម្មភាពជនពិការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងពិការភាព និងទទួលយកទៅអនុវត្ត
- ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅក្នុងក្រសួង
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការនៅក្នុងក្រសួង ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត គ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីជនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជា សុផារ៉ា

**<u>កន្លែងទទួលៈ</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ